រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នូវបញ្ញត្តិនានា ដែលពាក់ព័ន្ធចំពោះទំនិញដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា នេះរួមទាំងការលក់ ការផ្ទេរ ការបង្វែរ និងការបោះបង់ចោលក្រោមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះផង ។

**មាត្រា ២៨.-**

រដ្ឋបាលគយអាចផ្តល់បាននូវការបង្វិលសងវិញទាំងស្រុង ឬ ភាគខ្លះនូវពន្ធ និង អាករនាំចូលដែលបានបង់រួចចំពោះ :

ក- ការបង់លើសដោយប្រការណាមួយ រាប់បញ្ចូលទាំងករណីដែលបណ្តាល មកពីការភ័ន្តច្រឡំរដ្ឋបាលផង ។

ខ-ទំនិញនាំចូលដែលនៅមុនពេលអនុញ្ញាតឱ្យយកចេញពីគយត្រូវពិនិត្យ ឃើញថា តិចជាង បែកបាក់ខូចខាត គុណភាពទាប និងទំនិញនាំចេញទៅវិញ ឬ បំផ្លាញ ចោល ក្រោមការគ្រប់គ្រង ឃ្លាំមើលរបស់គយ ទោះបីនៅក្រោយពេលអនុញ្ញាតឱ្យយក ចេញពីគយរួចហើយក៏ដោយ ។

គ-ការបង់លើសដែលបានរកឃើញតាមរយៈសេចក្តីសម្រេចរបស់អាជ្ញាធរ ទទួលបន្ទុកដោះស្រាយការតវ៉ាដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ឬ ដោយតុលាការ មានសមត្ថកិច្ច ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសស្តីពីការបង្វិលសងវិញដែល បានរៀបរាប់ខាងលើ និងការបង្វិលសងវិញ ដោយមូលហេតុផ្សេងទៀតរួមទាំងការកម្រិត ពេលវេលាផងដែរ ។

## ជំពូកទី ៥

## ប្រតិវេទន៍គយ និងការទទួលខុសត្រូវចំពោះពន្ធ និងអាករ

**មាត្រា ២៩.-**

រាល់ទំនិញនាំចេញ ឬ នាំចូល ទោះជាជាប់ពន្ធ និងអាករក្តី ឬ ត្រូវបានលើកលែង ពន្ធ និងអាករ ទំនិញទាំងនោះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ ។



ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
23/45

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសពាក់ព័ន្ធនឹង :

-ទម្រង់ ខ្លឹមសារ និងសុពលភាពនៃប្រតិវេទន៍ និងឯកសារគយ

-ការតម្កល់ ការផ្ទៀងផ្ទាត់ និង ការចុះបញ្ជិកាប្រតិវេទន៍គយ

-ការកែប្រែ ការបន្ថែម និងការលុប ឬ ប្តូរនូវប្រតិវេទន៍ និង ឯកសារគយ

-ការបែងចែក និងគ្រប់គ្រងត្រួតពិនិត្យ ប្រតិវេទន៍ និងឯកសារគយ ។

**មាត្រា ៣១.-**

ទំនិញនាំចេញ ឬ នាំចូលត្រូវប្រកាសដោយម្ចាស់ទំនិញ ឬ ដោយបុគ្គលដែលបានទទួលការអនុញ្ញាតឱ្យបំពេញបែបបទគយក្នុងនាមម្ចាស់ទំនិញ ។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសផ្តល់ ឬដកមកវិញនូវការអនុញ្ញាតបាន ចំពោះបុគ្គលណាមួយជាជើងសាគយ និងកំណត់នូវទីតាំងដែលការអនុញ្ញាតនោះមានសុពលភាព និងល័ក្ខខ័ណ្ឌ ឬ លក្ខណៈសម្បត្តិនានាសម្រាប់ការអនុញ្ញាតនេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបង្កើតគណៈកម្មាធិការមួយបានសម្រាប់ផ្តល់យោបល់លើការអនុញ្ញាតនេះ និងរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជើងសាគយ ។

ការអនុញ្ញាតជាជើងសាគយ ត្រូវបានផ្តល់សម្រាប់ជនម្នាក់ៗ ។ ប្រសិនបើជាការស្នើសុំរបស់នីតិបុគ្គល ការអនុញ្ញាតនឹងត្រូវផ្តល់ជូននីតិបុគ្គលនោះ និងជនដែលទទួលសិទ្ធិជាតំណាង ។

ការបដិសេធ ការដកមកវិញនូវការអនុញ្ញាតជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍ជាជើងសាគយពុំត្រូវបានផ្តល់នូវសំណង ឬ ជម្ងឺចិត្តអ្វីឡើយ ។

ជើងសាគយដែលបានអនុញ្ញាត អាចត្រូវតម្កល់និមុត្តិធានាពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួនតាមទម្រង់ និងចំនួនទឹកប្រាក់ដូចដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៣.-**

បុគ្គលណាដែលគ្មានវិជ្ជាជីវៈជាជើងសាគយ អាចបំពេញប្រតិវេទន៍គយបានសម្រាប់



24/45

អាជីវកម្មខ្លួន ។

បុគ្គលដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះអាចទទួលបានការអនុញ្ញាតឱ្យបញ្ចេញទំនិញពីគយសម្រាប់អ្នកផងទៃ ។ ការអនុញ្ញាតនេះត្រូវបានផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបណ្ដោះអាសន្ន ហើយអាចដកហូតវិញបានសម្រាប់ប្រតិបត្តិការពាក់ព័ន្ធនឹងទំនិញដោយឡែកមួយចំនួន ។

**មាត្រា ៣៤.-**

ពន្ធ និងអាករនាំចូលត្រូវគណនាដោយផ្អែកលើមូលដ្ឋានអត្រាពន្ធ ឬ អាករ ជាធរមាននៅថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

ពន្ធ និងអាករនាំចូលត្រូវគណនាដោយផ្អែកលើមូលដ្ឋាន ពន្ធគិតតាមតម្លៃ ឬ ពន្ធគិតតាមឯកតា ។

**មាត្រា ៣៥.-**

អ្នកនាំចូល ឬ ម្ចាស់ទំនិញត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល ។

ក្នុងករណីដែលអ្នកនាំចូល ឬ ម្ចាស់ទំនិញមិនត្រូវបានរកឃើញ ភ្នាក់ងារជើងសាគយត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល ។

ក្នុងករណីសន្និធិគយបណ្ដោះអាសន្ន ឬ សន្និធិគយមានដែនកំណត់ ប្រតិបត្តិករនៃសន្និធិទាំងនេះ ជាអ្នកទទួលខុសត្រូវចំពោះពន្ធ អាករ និងកម្រៃផ្សេងៗដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលអាចត្រូវទទួល រហូតដល់ទំនិញត្រូវបាននាំចេញទៅវិញនាំចូលបណ្ដោះអាសន្ន នាំចូលដើម្បីប្រើប្រាស់ក្នុងប្រទេស បង្វែរទៅទីកន្លែងសន្និធិផ្សេងទៀត ឬបំផ្លាញចោលដោយមានការអនុញ្ញាតពីរដ្ឋបាលគយ ។

នៅក្នុងករណីមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះ ប្រសិនបើល័ក្ខខ័ណ្ឌនៃការលើកលែងពន្ធ និងអាករនាំចូលមិនត្រូវបានបំពេញសព្វគ្រប់ ការទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូលជាបន្ទុករបស់បុគ្គលដែលបានទទួលការលើកលែងពន្ធ និងអាករនាំចូល ប្រសិនបើមិនអាចរកឃើញបុគ្គលនោះ បន្ទុកនេះត្រូវធ្លាក់ទៅលើបុគ្គលដែលកាន់កាប់ទំនិញនោះ ។

ជននិណាដែលជាអ្នកកាន់កាប់ទំនិញនាំចូលនាពេលដែលមធ្យោបាយដឹកជញ្ជូនចូល



25/45

ក្នុងដែនគយ រាប់បញ្ចូលទាំងប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនផង ជននោះជាអ្នកទទួលខុសត្រូវលើពន្ធ និងអាករនាំចូលនៃទំនិញនោះ ។

**មាត្រា ៣៦.–**

អ្នកនាំចេញ ឬម្ចាស់ទំនិញត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

ក្នុងករណីដែលអ្នកនាំចេញ ឬ ម្ចាស់ទំនិញមិនអាចត្រូវបានរកឃើញជើងសាគយត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

ក្នុងករណីសន្និធិគយណ្ដោះអាសន្ន និងសន្និធិគយមានដែនកំណត់ ប្រតិបត្តិករនៃសន្និធិទាំងនេះត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

## ជំពូកទី ៦

## ការបង់ប្រាក់ពន្ធ និងអាករនាំចូល និងនាំចេញ ការប្រមូលបំណុល និងនិម្មិតធានា

**មាត្រា ៣៧.–**

ពន្ធ និងអាករនាំចេញ និងនាំចូល ព្រមទាំងកម្រៃមានការអនុញ្ញាត ការពិន័យ ការប្រាក់ ឬ ទោសទណ្ឌដែលត្រូវជាប់ក្រោមច្បាប់នេះ និងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង់នៅកន្លែង តាមរបៀប និង ពេលវេលាកំណត់ ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ពន្ធ និងអាករដែលត្រូវបង់សម្រាប់មុខទំនិញនីមួយៗក្នុងប្រតិវេទន៍គយតែមួយត្រូវគិតជាប្រាក់រៀលដោយដំឡើងដល់ខ្ទង់រយជិតបំផុត ។

បង្កាន់ដៃត្រូវបានផ្ដល់សម្រាប់រាល់ការចំណាយដែលបានបង់ ។

**មាត្រា ៣៨.–**

បំណុលដែលជំពាក់ស្របតាមបញ្ញត្តិនៃច្បាប់នេះហើយពុំបានបង់ទាំងស្រុង ឬភាគខ្លះ តាមពេលវេលាកំណត់ ត្រូវជាប់ការប្រាក់គរពូន ទៅតាមអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។